# មហាវិទ្យាល័យវិស្វកម្មអគ្គិសនីនៃសាកលវិទ្យាល័យក្វាងស៊ី

# (មហាវិទ្យាល័យថាមពលចិន-អាស៊ាន)

# កម្មវិធីអាហារូបករណ៍របស់ក្រុមហ៊ុនChina Southern Power Grid(CSG)ឆ្នាំ 2025

# មគ្គុទ្ទេសក៍ណែនាំស្តីពីការចុះឈ្មោះនិស្សិតអន្តរជាតិ

សូមស្វាគមន៍សិស្សនិស្សិតដាក់ពាក្យចូលរៀនមហាវិទ្យាល័យវិស្វកម្មអគ្គិសនីនៃសាកលវិទ្យាល័យក្វាងស៊ី (មហាវិទ្យាល័យថាមពលចិន-អាស៊ាន)!   សាកលវិទ្យាល័យក្វាងស៊ីគឺជាសាកលមួយដែលចាត់បញ្ចូលជាគម្រោងថ្នាក់ជាតិ "គម្រោង 211 "   ជាសាកលវិទ្យាល័យមួយដែលមាន"double standards " និងជាសាកលវិទ្យាល័យ "ការសាងសង់រួមគ្នា" ដោយក្រសួងអប់រំនិងរដ្ឋាភិបាលរបស់ប្រជាជននៃតំបន់ស្វយ័តជនជាតិជាំង។ សាកលវិទ្យាល័យក្វាងស៊ីមានធនធានអប់រំនិងបរិយាកាសសិក្សាដ៏ទូលំទូលាយ។ មហាវិទ្យាល័យវិស្វកម្មអគ្គិសនីនៃសាកលវិទ្យាល័យក្វាងស៊ី (មហាវិទ្យាល័យថាមពលចិន-អាស៊ាន) ត្រូវបានបង្កើតឡើងក្នុងឆ្នាំ 1938ដែលមានទីតាំងនៅទីក្រុងណាននីងស្ថិតនៅតំបន់ស្វយ័តខេត្តក្វាងស៊ី។ ទីក្រុងណាននីងមិនត្រឹមតែជា "ទីក្រុងបៃតង " ដ៏ស្រស់ស្អាតប៉ុណ្ណោះទេ ថែមទាំងជាទីក្រុងព្រំដែនសម្រាប់ការបើកទូលាយចំពោះកិច្ចសហប្រតិបត្តិការរវាង ប្រទេសចិនជាមួយនឹងតំបន់អាស៊ានផងដែរ។ បច្ចុប្បន្ននេះមហាវិទ្យាល័យមានជំនាញសិក្សាថ្នាក់បរិញ្ញាបត្រលំដាប់ថ្នាក់ជាតិ(វិស្វកម្មអគ្គិសនីនិងស្វ័យប្រវត្តិកម្ម) ហើយក៏ត្រូវបានអនុញ្ញាតឱ្យផ្តល់សញ្ញាបត្រថ្នាក់អនុបណ្ឌិត និងថ្នាក់បណ្ឌិតផ្នែកវិស្វកម្មអគ្គិសនីផងដែរ។ មហាវិទ្យាល័យយើងប្រមូលផ្តុំទៅដោយគ្រូបង្រៀនជម្រើសថ្នាក់ជាតិហើយបានបង្កើតជាវេទិកាសិក្សាអប់រំថ្នាក់ជាតិ ថែមទាំងមានការបំពាក់គ្រឿងបរិក្ខារបង្រៀនគ្រប់គ្រាន់ ប្រកបដោយហេដ្ឋារចនាសម្ព័ន្ធបែបទំនើប។

អាហារូបករណ៍China Southern Power Grid (CSG) គឺជាអាហារូបករណ៍ផ្តល់អោយពេញលេញដែលបង្កើតឡើងដោយក្រុមហ៊ុន China Southern Power Grid Co., Ltd. រួមសហការជាមួយនឹងសាកលវិទ្យាល័យក្វាងស៊ីដើម្បីបណ្តុះបណ្តាលសិស្សនិស្សិតថ្នាក់បរិញ្ញាបត្រ (និស្សិតអន្តរជាតិ) ជំនាញផ្នែកវិស្វកម្មអគ្គិសនីនិងស្វ័យប្រវត្តិកម្ម និងនិស្សិតថ្នាក់អនុបណ្ឌិត

(និស្សិតអន្តរជាតិ) ជំនាញវិស្វកម្មអគ្គិសនីដើម្បីបំពេញតម្រូវការនៃការអភិវឌ្ឍន៍អាជីវកម្មរបស់ក្រុមហ៊ុននៅក្នុងបណ្តាប្រទេសជាសមាជិកអាស៊ាន។
ខាងក្រោមនេះជាសេចក្តីណែនាំសង្ខេបអំពីព័ត៌មានលម្អិតនៃអាហារូបករណ៍សម្រាប់ការសិក្សានៅប្រទេសចិនៈ

## ១. ប្រភេទនៃសិស្សនិស្សិតចូលរៀននិងអាហារូបករណ៍

| ប្រភេទនៃការសិក្សា | ជំនាញសិក្សា | ឆ្នាំកំណត់សិក្សា | វគ្គបណ្តុះបណ្តាលភាសាចិន | រយៈពេលអាហារូបករណ៍ | កម្មវិធីសិក្សា |
|---|---|---|---|---|---|
| ថ្នាក់បរិញ្ញាបត្រ | បរិញ្ញាបត្រវិស្វកម្មអគ្គិសនីនិងស្វ័យប្រវត្តិកម្ម | ៤ឆ្នាំ | ១ឆ្នាំ | ១+៤ឆ្នាំ | ពេញម៉ោងសិក្សា |
| ថ្នាក់អនុបណ្ឌិត | វិស្វកម្មអគ្គិសនី | ៣ឆ្នាំ | - | 0+៣ឆ្នាំ | ពេញម៉ោងសិក្សា |

ចំណាំ÷ ១) ប្រសិនបើបេក្ខជនដាក់ពាក្យមានសញ្ញាបត្រភាសាចិនដល់កំរិត HSK ៤ ឬខ្ពស់ជាងនេះបេក្ខជនអាចស្នើរចូលសិក្សាជំនាញតែម្តងដោយមិនបាច់រៀនត្រៀមភាសាចិនមួយឆ្នាំនោះទេ។ ហើយបញ្ជាក់ផងដែរថាបេក្ខជននឹងមិនមានសិទ្ធិទទួលបានថ្លៃអាហារូបករណ៍សិក្សាភាសាចិនរយៈពេលមួយឆ្នាំនោះទេ។

២) ភាសានៃការបង្រៀន÷ លើកលែងតែឆ្នាំថ្នាក់ភាសាចិន១ឆ្នាំដំបូងនៃការសិក្សាភាសាចិន ភាសានៃការបង្រៀនគឺបង្រៀនជាភាសាចិន។

## ២. ប្រព័ន្ធកម្មវិធីសិក្សានិងឆមាសសិក្សា

កម្មវិធីសិក្សាសំរាប់ថ្នាក់បរិញ្ញាបត្រមានរយៈពេល ៤ឆ្នាំ និងថ្នាក់ថ្នាក់អនុបណ្ឌិតមានរយៈពេល ៣ ឆ្នាំ។
រាល់ឆ្នាំសិក្សានៅសាកលវិទ្យាល័យក្វាងស៊ីចែកចេញជាពីរឆមាស÷ និទាឃរដូវ(Spring)និងរដូវស្លឹកឈើជ្រុះ(Autumn)។ ឆមាសរដូវស្លឹកឈើជ្រុះ(Autumn)គឺជាការបើកបវេសនកាលចាប់

ផ្តើមនៃឆ្នាំសិក្សាថ្មីជាទូទៅចាប់ពីខែកញ្ញាដល់ខែមករាហើយឆមាសនិទាឃរដូវ(Spring) ចាប់ពីខែកុម្ភៈដល់ខែមិថុនា។

## ៣. លក្ខខណ្ឌសម្រាប់ស្នើរសុំចុះឈ្មោះ

១. ពលរដ្ឋមិនមែនជាជនជាតិចិន កាន់លិខិតឆ្លងដែនបរទេសដែលមានសុពលភាព។

២. បេក្ខជនដែលមានសញ្ជាតិជាប្រទេសក្នុងតំបន់អាស៊ាន និងបុគ្គលិកដែលត្រូវបានចាត់តាំងដោយក្រុមហ៊ុន China Southern Power Grid (CSG) សម្រាប់គម្រោងក្រៅប្រទេស។

៣. មានសុខភាពល្អទាំងផ្លូវកាយ និងផ្លូវចិត្ត និងបំពេញតាមស្តង់ដារពិនិត្យសុខភាពសម្រាប់ការដាក់ពាក្យសុំទិដ្ឋាការសិក្សា ឬប័ណ្ណស្នាក់នៅក្នុងប្រទេសចិន។

៤. បេក្ខជនដែលមកប្រទេសចិនដើម្បីបន្តការសិក្សាថ្នាក់អនុបណ្ឌិតត្រូវតែមានសញ្ញាបត្រដែលមានតំលៃស្មើនឹងថ្នាក់បរិញ្ញាបត្រពីសាកលវិទ្យាល័យចិន។

៥. បេក្ខជនត្រូវមានភាពរួសរាយរាក់ទាក់ ឧស្សាហ៍ព្យាយាម និងខិតខំរៀនសូត្រ មានសមត្ថភាពសិក្សាល្អ អាកប្បកិរិយាល្អ និងគោរពច្បាប់។ បេក្ខជនត្រូវតែមិនមានកំណត់ត្រានៃការបំពានច្បាប់ និងបទប្បញ្ញត្តិនានារបស់សាលា គ្មានការពិន័យសន្តិសុខសាធារណៈ និងគ្មានកំណត់ត្រាព្រហ្មទណ្ឌ។

៦. កំរិតភាសា÷ បេក្ខជនដែលដាក់ពាក្យមកសិក្សានៅប្រទេសចិនថ្នាក់អនុបណ្ឌិតចាំបាច់ត្រូវតែមានភាសាចិន កម្រិត៤ ដែលមានពិន្ទុចាប់ពី 180 ឡើងទៅ។

៧. បេក្ខជនស្នើរសុំអាហារូបករណ៍សម្រាប់ថ្នាក់បរិញ្ញាបត្រត្រូវមានអាយុក្រោម ៣០ ឆ្នាំ (កើតក្រោយថ្ងៃទី ០១ ខែកញ្ញា ឆ្នាំ ១៩៩៤) ហើយបេក្ខជនអាហារូបករណ៍សម្រាប់ថ្នាក់អនុបណ្ឌិតត្រូវតែមានអាយុក្រោម ៣៥ ឆ្នាំ (កើតក្រោយថ្ងៃទី ០១ ខែកញ្ញា ឆ្នាំ ១៩៩០)។

## ៤. នីតិវិធីនៃការស្នើរសុំអាហារូបករណ៍

ការចុះឈ្មោះសិស្សនិស្សិតអន្តរជាតិឆ្នាំ ២០២៥នេះ គឺកំពុងតែបើកដំណើរការអោយដាក់ពាក្យ។ ឆមាសថ្មីនឹងចាប់ផ្តើមនៅថ្ងៃទី ២៦ ខែសីហា ឆ្នាំ ២០២៥។ ប្រសិនបើអ្នកមានបំណងចង់មកសិក្សានៅមហាវិទ្យាល័យវិស្វកម្មអគ្គិសនីនៃសាកលវិទ្យាល័យក្វាងស៊ីសូមអានការណែនាំអំពីនីតិវិធីនៃការដាក់ពាក្យខាងក្រោមដោយយកចិត្តទុកដាក់។

### (១) ចូលទៅក្នុងប្រព័ន្ធដើម្បីចុះឈ្មោះ

បេក្ខជនអាចដាក់ពាក្យតាមអ៊ីនធឺណិត(Online Application) តាមវិធីខាងក្រោមសូមចុចលីងខាងក្រោមដើម្បីដាក់ពាក្យតាមអនឡាញ÷

http://gxu.at0086.cn/StuApplication/Login.aspx

ឬស្កេន QR កូដខាងក្រោមដើម្បីចុះឈ្មោះតាមអ៊ីនធឺណិត÷

扫 码 报 名

APPLY NOW

Scan or long press the above QR code
for the access to Online Application System

**(២)ជ្រើសរើសកម្មវិធីចុះឈ្មោះអាហារូបករណ៍**

នៅពេលបេក្ខជនស្នើរសុំការដាក់ពាក្យគ្រាន់តែតម្រូវអោយបង្កើតគណនីផ្ទាល់ខ្លួនជាមួយនឹងអាសយដ្ឋានអ៊ីមែលរបស់អ្នកហើយអ្នកហ្នឹងអាចចាប់ផ្តើមដាក់ពាក្យបានភ្លាមៗ។នៅក្នុងប្រព័ន្ធបំពេញពាក្យត្រូវជ្រើសរើស "中国南方电网公司奖学金" នៅក្នុង "កម្មវិធីចុះឈ្មោះ"។

**(៣)បង្ហោះឯកសារស្នើរសុំដែលពាក់ព័ន្ធដូចខាងក្រោម÷**

ប្រសិនបើបេក្ខជនដាក់ពាក្យស្នើរសុំថ្នាក់បរិញ្ញាបត្រតម្រូវអោយផ្តល់ឯកសារដូចខាងក្រោមលេខ ១, ២, ៣, ៤, ៥, ៦, និង ៩។

ប្រសិនបើបេក្ខជនដាក់ពាក្យស្នើរសុំអាហារូបករណ៍ដើម្បីសិក្សាថ្នាក់ក្រោយឧត្តមសិក្សាសូមផ្តល់ឯកសារខាងក្រោម ១, ២, ៣, ៤, ៥, ៦, ៧, ៨, ៩។

១. រូបថត (ថតពាក់កណ្តាលខ្លួនជាមួយនឹងផ្ទៃខាងក្រោយពណ៌ស)

២.វិញ្ញាបនបត្រសុខភាព( ទម្រង់បែបបទពិនិត្យសុខភាពអាចទាញយកបានពីតំណនេះ https://gjxy.gxu.edu.cn/gjxy_en/info/1035/1151.htm)

៣. ថតចម្លងលិខិតឆ្លងដែន (ទំព័ររូបថត និងទំព័រទិដ្ឋាការ)

៤. វិញ្ញាបនបត្រ HSK (កម្រិត ៤ ឬខ្ពស់ជាងនេះ)

៥. វិញ្ញាបនបត្រសិក្សាខ្ពស់បំផុត (ឯកសារត្រូវបកប្រែជាភាសាចិន ឬអង់គ្លេស)

៦. ព្រឹត្តិបត្រពិន្ទុសិក្សាខ្ពស់បំផុត (ឯកសារត្រូវបកប្រែជាភាសាចិន ឬអង់គ្លេស)

៧. លិខិតអនុសាសន៍ចំនួនពីរច្បាប់ជាភាសាអង់គ្លេស ឬភាសាចិនដែលសរសេរដោយសាស្ត្រាចារ្យរង ឬលើសពីនេះ (និស្សិតថ្នាក់អនុបណ្ឌិត តម្រូវឱ្យផ្តល់ឯកសារនេះ)

៨. ផែនការសិក្សា (និស្សិតថ្នាក់អនុបណ្ឌិត តម្រូវឱ្យផ្តល់ឯកសារនេះ)

៩. លិខិតថ្កោលទោស

**(៤) ដាក់ពាក្យស្នើសុំ**

បន្ទាប់ពីបំពេញទម្រង់បែបបទពាក្យស្នើរសុំនិងបញ្ចូលឯកសារដែលពាក់ព័ន្ធរួចហើយ បេក្ខជនត្រូវចុចពាក្យស្នើសុំក្នុងប្រព័ន្ធចុះឈ្មោះ។

## ៥. អំពីដំណើរការជ្រើសរើស

ការស្នើរសុំដាក់ពាក្យត្រូវចំណាយពេលយ៉ាងហោចណាស់ ៤-៨សប្តាហ៍ចាប់ពីថ្ងៃផុតកំណត់នៃការដាក់ពាក្យរហូតដល់ការចេញព័ត៌មានចូលរៀន។ ក្នុងអំឡុងពេលនេះ យើងនឹងជូនដំណឹងដល់បេក្ខជនឱ្យបំពេញរាល់ឯកសារពាក់ពាន់ទាំងអស់ ហើយសហការជាមួយក្រុមហ៊ុន Guangxi Power Grid ដើម្បីពិនិត្យនិងវាយតម្លៃឯកសារ និងរៀបចំធ្វើការសម្ភាសន៍។ ប្រសិនបើបេក្ខជន ត្រូវបានជ្រើសរើស យើងនឹងផ្ញើរជូននូវការជូនដំណឹងអំពីការចូលរៀន និងឯកសារពាក់ព័ន្ធនានា។ យើងនឹងព្យាយាមផ្ញើរព័ត៌មាននៃការចូលរៀនឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន។

## ៦. ដំណើរការស្នើរសុំទិដ្ឋាការ

សូមយកលិខិតចុះឈ្មោះចូលរៀន និងពាក្យស្នើរសុំទិដ្ឋាការដែលចេញដោយសាកលវិទ្យាល័យរបស់យើងទៅស្ថានទូតចិនដែលស្ថិតនៅក្នុងប្រទេសរបស់អ្នក ដើម្បីដាក់ពាក្យស្នើរសុំទិដ្ឋាការសិស្ស។ បន្ទាប់ពីបានមកដល់សាកលវិទ្យាល័យក្វាងស៊ីសូមដាក់ពាក្យស្នើរសុំសិទ្ធិស្នាក់នៅសិក្សា។ លុះត្រាតែសិស្សនិស្សិតមានប័ណ្ណស្នាក់នៅប្រទេសចិន ទើបមានសិទ្ធិអាចសិក្សា និងរស់នៅក្នុងប្រទេសចិនបានដោយស្របច្បាប់។

សូមចំណាំ÷ ប័ណ្ណស្នាក់នៅគឺជាឯកសារសំខាន់សម្រាប់លំនៅដ្ឋានរបស់អ្នកនៅក្នុងប្រទេសចិន។ សាកលវិទ្យាល័យក្វាងស៊ីនឹងជួយអ្នកក្នុងការស្នើសុំលិខិតអនុញ្ញាតស្នាក់នៅបន្ទាប់ពីបញ្ជាក់ការចូលរៀននិងបង់ថ្លៃសិក្សា។

## ៧. ថ្ងៃផុតកំណត់នៃការដាក់ពាក្យ

ដើម្បីធានាថាសកម្មភាពបង្រៀនត្រូវបានអនុវត្តប្រកបដោយសណ្តាប់ធ្នាប់ សូមបំពេញការចុះឈ្មោះនៅថ្ងៃទី ៣០ ខែមិថុនា មុនម៉ោង ២៤:០០ ម៉ោងនៅទីក្រុងប៉េកាំង។

## ៨. ព័ត៌មានទាក់ទងនឹងអាហារូបករណ៍

ប្រាក់ឧបតម្ភសម្រាប់និស្សិតអន្តរជាតិនីមួយៗរួមមានថ្លៃសិក្សា កន្លែងស្នាក់នៅ ការចំណាយលើការរស់នៅ ធានារ៉ាប់រង និងការចំណាយផ្សេងៗទៀត។ ការចំណាយលើការរស់នៅរួមមានប្រាក់ឧបត្ថម្ភការរស់នៅ ផ្នែកនៃថ្លៃព្យាបាល ថ្លៃពិនិត្យសុខភាព ថ្លៃសុំទិដ្ឋាការ/ថ្លៃស្នាក់នៅ ថ្លៃដឹកជញ្ជូន ថ្លៃចុះឈ្មោះប្រលង HSK-៤/HSK-៥ថ្លៃសម្ភារៈសិក្សា។ល។

## ៩.កន្លែងស្នាក់នៅ

និស្សិតថ្នាក់បរិញ្ញាបត្រ និងនិស្សិតថ្នាក់អនុបណ្ឌិតទាំងអស់នៃសាកលវិទ្យាល័យក្វាងស៊ីត្រូវបានស្នាក់នៅអគារនិស្សិតអន្តរជាតិរបស់សាកលវិទ្យាល័យដោយក្នុងមួយបន្ទប់សម្រាប់មនុស្ស ៤ នាក់ ។

## ១០. ទាក់ទងមកយើងខ្ញុំ

លោកគ្រូChen ការិយាល័យមជ្ឈមណ្ឌលសេវាកម្មនិស្សិតអន្តរជាតិនៃសាកលវិទ្យាល័យក្វាងស៊ី

អ៊ីមែល÷ lxs@gxu.edu.cn

ទូរស័ព្ទ÷ +86-771-3235229

WeChat÷ STUDY-AT-GXU

គេហទំព័រ÷ www.gxu.edu.cn

gjxy.gxu.edu.cn

លោកគ្រូ Zhou មហាវិទ្យាល័យវិស្វកម្មអគ្គិសនីនៃសាកលវិទ្យាល័យក្វាងស៊ី

លោកគ្រូ He មហាវិទ្យាល័យវិស្វកម្មអគ្គិសនីនៃសាកលវិទ្យាល័យក្វាងស៊ី

អ៊ីមែល÷ dqxylxs@gxu.edu.cn

ទូរស័ព្ទ÷ +86-771-3224191

WeChat÷ (កំណត់)

គេហទំព័រ÷ www.gxu.edu.cn

លោកគ្រូ Wang មជ្ឈមណ្ឌលអភិវឌ្ឍន៍ទេពកោសល្យនៃក្រុមហ៊ុនបណ្ដាញថាមពលក្វាងស៊ី

អ៊ីមែល÷ 3088138213@qq.com

ទូរស័ព្ទ÷ +86-771-5693857

WeChat: sugarbutter123